# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៣៨ ប្រក

ថ្ងៃ សុក្រ ៧រោច ខែ បុស្ស ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៣

# ប្រកាស
## ស្តីពី
## ការដាក់ឲ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មការអន្តរក្រសួង គ.អ.ច.ទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញសេចក្តីសម្រេចលេខ ០១ សសរ ចុះថ្ងៃទី ៤ ខែមករា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស "គ.អ.ច.ទ"
- យោងតាមភាពចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១._**

ប្រកាសនេះមានគោលបំណងដាក់ឲ្យអនុវត្ត "នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក" ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីផ្តល់ភាពងាយស្រួលដល់សមត្ថកិច្ច និងកាត់បន្ថយភាពស្មុគស្មាញរបស់ទេសចរបើកបរដោយខ្លួនឯងក្នុងពេលឆ្លងកាត់ការត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែននៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីពង្រឹងភាពទាក់ទាញនៃវិស័យទេសចរណ៍បើកបរដោយខ្លួនឯង។

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣._**

ប្រកាសនេះនិរាករប្រកាស ដូចខាងក្រោម៖

- ប្រកាសលេខ ០៣០ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្ដីពីការដាក់ឲ្យអនុវត្តវិធានសុវត្ថិភាព និងវិធានសម្រួលការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោករបស់គណៈកម្មការអន្តរក្រសួង គ.អ.ច.ទ
- ប្រកាសលេខ ០៣៦ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ស្ដីពីការដាក់ឲ្យអនុវត្តវិធានសុវត្ថិភាព និងវិធានសម្រួលការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោករបស់គណៈកម្មការអន្តរក្រសួង គ.អ.ច.ទ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស និងលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**
**និងជាប្រធានគណៈកម្មការអន្តរក្រសួង គ.អ.ច.ទ**

**ថោង ខុន**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចឯកឧត្តមលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ